# ព្រះគម្ពីរមរមន---ជាព្រះគម្ពីរមកពីព្រះ

*ដោយអែលឌើរ ថាត អរ ខាលីស្ទើរ*
*នៃគណៈប្រធាននៃពួកចិតសិបនាក់*

ជាច្រើនឆ្នាំកន្លងមកហើយ លោកតាលួតរបស់ខ្ញុំបានរើសយកព្រះគម្ពីរមរមនជាលើកដំបូង ។ គាត់បានបើកទៅពាក់កណ្ដាលទំព័រ ហើយបានអានវាពីរបីទំព័រ ។ ក្រោយមកគាត់បានប្រកាស « ថាសៀវភៅនេះត្រូវបានសរសេរឡើងដោយព្រះ ឬអារក្ស ខ្ញុំនឹងស្វែងយល់ថា តើនរណាបានសរសេរសៀវភៅនេះ » ។ ក្នុងរយៈពេលតែ 10 ថ្ងៃក្រោយមកគាត់បានអានវាចប់ពីរដង រួចគាត់បានប្រកាសថា « អារក្សមិនអាចសរសេរសៀវភៅនេះបានទេ---វាត្រូវតែបានសរសេរឡើងដោយព្រះ » ។[1]

នោះគឺជាទស្សនវិស័យដ៏អស្ចារ្យពីព្រះគម្ពីរមរមន---វាគ្មាននូវអព្យាក្រិតភាព ។ វាគឺជាព្រះបន្ទូលរបស់ព្រះ ដូចដែលបានប្រកាស ឬក៏វាជាការបោក-បញ្ឆោតទាំងស្រុង ។ គម្ពីរនេះ ពុំបានថ្លែងរៀបរាប់ពីសីលធម៌ ឬអត្ថាធិប្បាយពីសាសនាវិទ្យា ឬជាការប្រមូលផ្ដុំនៃការសរសេរដែលយល់ច្បាស់លាស់នោះទេ ។ វាប្រកាសព្រះបន្ទូលរបស់ព្រះ---នៅគ្រប់ប្រយោគ គ្រប់ខ គ្រប់ទំព័រ ។ យ៉ូសែប ស្ម៊ីធ បានប្រកាសថា មានទេវតារបស់ព្រះមួយអង្គ បានណែនាំគាត់ឲ្យយកផ្ទាំងចំណារមាស ដែលមាននូវការសរសេរទាំងឡាយរបស់ពួកព្យាការី ស្ដីពីប្រទេសអាមេរិកកាលពីបុរាណ ហើយថាគាត់បកប្រែផ្ទាំងចំណារទាំងនោះ ដោយព្រះចេស្ដាដ៏ទេវភាព ។ បើនោះជារឿងពិត នោះព្រះគម្ពីរមរមន ជាព្រះគម្ពីរដ៏ពិសិដ្ឋ ដូចដែលវាបានប្រកាស ប៉ុន្តែប្រសិនបើវាមិនពិត នោះវាជារឿងដ៏ស្មុគស្មាញ មិនតែប៉ុណ្ណោះ ជាការបោកបញ្ឆោតមកពីអារក្ស ។

ស៊ី អេស លូវិស បាននិយាយពីកង្វល់ស្រដៀងគ្នានោះ ដែលបានពិសោធន៍ដោយមនុស្សម្នាក់ ដែលត្រូវតែទទួលយក ឬបដិសេធនូវទេវភាពរបស់ព្រះអង្គសង្គ្រោះ---ក៏ដូចគ្នាទៅនឹងការគ្មានអព្យាក្រិតភាព ៖ « ខ្ញុំនៅទីនេះកំពុងព្យាយាមការពារមនុស្សណាដែលនិយាយនូវរឿងឆ្កួតលីលាដែលមនុស្សតែងនិយាយអំពីទ្រង់ជាញឹកញាប់ថា ៖ ‹ ខ្ញុំទទួលស្គាល់យេស៊ូវថា ជាគ្រូបង្រៀនខាងសីលធម៌ដ៏អស្ចារ្យម្នាក់រួចទៅហើយ ប៉ុន្តែខ្ញុំមិនទទួលស្គាល់ការប្រកាសរបស់គាត់ថាជាព្រះនោះទេ › ។ នោះជារឿងដែលយើងមិនត្រូវនិយាយទាល់តែសោះ ។ មនុស្សម្នាក់ដែលគ្រាន់តែជាមនុស្ស ហើយនិយាយនូវរឿងខ្លះៗដែលព្រះយេស៊ូវបានមានបន្ទូលនោះពុំមែនជាគ្រូបង្រៀនខាងសីលធម៌ដ៏អស្ចារ្យទេ ។...អ្នកត្រូវតែជ្រើសរើស ។ តើបុរសនេះជាមនុស្ស ឬជាព្រះរាជបុត្រារបស់ព្រះ ៖ ឬជាមនុស្សឆ្កួតលីលា ឬជាអ្វីដែលអាក្រក់បំផុត ។...ប៉ុន្តែសូមយើងកុំលើកឡើងនូវអ្វីដែលជាគំនិតដែលគ្មានន័យអំពីភាពជាគ្រូបង្រៀនដ៏អស្ចារ្យរបស់ទ្រង់ឡើយ ។ ទ្រង់មិនបន្សល់ទុកនូវការយល់ដឹងបែបនោះដល់យើងឡើយ ។ ទ្រង់ពុំសព្វព្រះទ័យឲ្យយើងយល់បែបនោះឡើយ ។[2]

ទន្ទឹមនឹងនោះដែរ យើងត្រូវតែជ្រើសរើសជម្រើសដ៏សាមញ្ញមួយជាមួយនឹងព្រះគម្ពីរមរមន---តើវាមកពីព្រះ ឬក៏មកពីអារក្ស ។ វាគ្មានជម្រើសផ្សេងទៀតទេ ។ ខ្ញុំអញ្ជើញអ្នកឲ្យធ្វើការសាកល្បងមួយភ្លែត ដែលនឹងជួយអ្នកឲ្យកំណត់ពីលក្ខណៈពិតនៃគម្ពីរនេះ ។ ចូរសួរខ្លួនអ្នកប្រសិនបើបទគម្ពីរខាងក្រោមចេញពីព្រះគម្ពីរមរមនជួយអ្នកឲ្យខិតកាន់តែជិតព្រះ ឬកាន់តែជិតអារក្ស ៖ « សូមទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ ត្បិតមើលចុះព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ នឹងប្រាប់ដល់អ្នកនូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ » ( នីហ្វៃទី2 32:3) ។

ឬនូវពាក្យទាំងនេះរបស់ឪពុកជាទីស្រឡាញ់ទៅកាន់កូនប្រុសទាំងឡាយរបស់គាត់ ៖ ហើយឥឡូវនេះ ឱកូនប្រុសទាំងឡាយរបស់ឪពុកអើយ ចូរចងចាំចុះ ចូរចងចាំចុះថា គឺនៅលើសិលានៃព្រះដ៏ប្រោសលោះនៃយើងគឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រា នៃព្រះដែលកូនត្រូវសាងគ្រឹះរបស់កូន » ( ហេលេមិន 5:12 ) ។ ឬពាក្យទាំងនេះរបស់ព្យាការីម្នាក់ ៖ « ចូរមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ » (មរ៉ូណៃ 10:32 ) ។

តើសេចក្ដីថ្លែង ចេញពីព្រះគម្ពីរមរមនទាំងនេះ អាចត្រូវបាននិពន្ធឡើងដោយអារក្សមែនឬ ? ក្រោយពីព្រះអង្គសង្គ្រោះបានបណ្ដេញពួកអារក្សចេញនោះពួកផារ៉ាស៊ី បានប្រកាសថា មនុស្សនេះដេញអារក្សបាន «ដោយសារបេលសេប៊ូលជាមេអារក្ស » ។ ព្រះសង្គ្រោះបានតបវិញថា គំនិតនោះពុំមានន័យទេ ៖ ទ្រង់បានមានបន្ទូលថា «អស់ទាំងនគរណា » « ដែលបែកទាស់តែគ្នាឯងនោះ នឹងត្រូវវិនាសទៅ ហើយអស់ទាំង...ផ្ទះណាដែលបែកទាស់តែគ្នាឯង នោះនឹងនៅស្ថិតស្ថេរពុំបានទេ » ។ ហើយនៅចំណុចចុងក្រោយរបស់ទ្រង់ ទ្រង់ទូលថា « ដូច្នេះបើអារក្សដេញអារក្សនោះមុខជាវាបែកទាស់គ្នាវាហើយ យ៉ាងនោះធ្វើដូចម្ដេចឲ្យរាជ្យវាស្ថិតស្ថេរនៅបាន ? » ( ម៉ាថាយ 12:24—26 សង្កត់ន័យថែម ) ។

ប្រសិនបើបទគម្ពីរដែលខ្ញុំបានលើកឡើងចេញពីព្រះគម្ពីរមរមនបង្រៀនយើងឲ្យថ្វាយបង្គំ និងស្រឡាញ់ ហើយបម្រើដល់ព្រះអង្គសង្គ្រោះ (ដែលពួកគេធ្វើ ) តើបទគម្ពីរនោះចេញមកពីអារក្សបានដោយរបៀបណា ? ប្រសិនបើដូច្នោះ នោះវានឹងបែកទាស់គ្នាវាហើយ ដូច្នោះវាបំផ្លាញនគររបស់វាផ្ទាល់

ហើយនេះជាស្ថានភាពពិតប្រាកដដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា មិនអាចនៅស្ថិតស្ថេរបានទេ ។ ការអានព្រះគម្ពីរ មរមនដោយស្មោះសរ ខ្ជាប់ខ្ជួន នឹងនាំមនុស្សម្នាក់ទៅរកគំនិតដូចដែលលោកតាលួតរបស់ខ្ញុំបានលើកឡើង ៖ « អារក្សមិនអាចសរសេរសៀវភៅនេះបានទេ---វាត្រូវតែបានសរសេរឡើងដោយព្រះ » ។

ប៉ុន្តែហេតុអ្វីបានជាព្រះគម្ពីរមរមនមានសារៈសំខាន់ ប្រសិនបើយើងមានគម្ពីរប៊ីបបង្រៀនយើង អំពីព្រះយេស៊ូវគ្រីស្ទហើយនោះ ? តើអ្នកធ្លាប់ឆ្ងល់ទេថា ហេតុអ្វីបានជាមានព្រះវិហារគ្រីស្ទានច្រើនម្លេះនៅក្នុងពិភពលោកសព្វថ្ងៃនេះ ខណៈដែលពួកគេបានទទួលគោលលទ្ធិទាំងឡាយរបស់គេចេញពីព្រះគម្ពីរប៊ីបដូចគ្នានោះ ? នោះដោយសារតែពួកគេបកស្រាយគម្ពីរប៊ីបខុសៗគ្នា ។ ប្រសិនបើពួកគេបកស្រាយដូចគ្នា នោះពួកគេនឹងមានព្រះវិហារដូចគ្នា ។ នេះពុំមែនជាស្ថានភាពដែលព្រះអម្ចាស់សព្វព្រះទ័យនោះទេ ត្បិតសាវកប៉ុលបានប្រកាសថា មាន « ព្រះអម្ចាស់តែមួយ សេចក្តីជំនឿតែមួយ បុណ្យជ្រមុជទឹកតែមួយ » ( អេភេសូរ 4:5 ) ។ ដើម្បីជួយនាំមកនូវសេចក្តីបញ្ជាក់ អំពីរបស់តែមួយ នោះព្រះអម្ចាស់បានបង្កើតនូវច្បាប់ដ៏ទេវភាពអំពីពួកសាក្សី ។ ប៉ុលបានបង្រៀនថា « គ្រប់ការណ៍ទាំងអស់ នឹងបានសម្រេចដោយនូវមាត់ស្មរបន្ទាល់ពីរឬបីនាក់ »
(កូរិនថូសទី2 13:1 ) ។

ព្រះគម្ពីរប៊ីបជាសាក្សីមួយអំពីព្រះគ្រីស្ទ ព្រះគម្ពីរមរមនជាសាក្សីមួយទៀត ។ ហេតុអ្វីបានជាសាក្សីទីពីរនេះសំខាន់ម្លេះ ? គំរូជំនួយចក្ខុខាងក្រោមអាចជួយបាន ៖ តើអ្នកអាចគូសបន្ទាប់ត្រង់បានប៉ុន្មាននៅលើក្រដាសមួយ តាមរយៈចំណុចតែមួយ ? ចម្លើយ គឺអានន្ទ ។ សូមសញ្ជឹងគិតមួយភ្លែតថា ចំណុចមួយតំណាងឲ្យគម្ពីរប៊ីប ហើយបន្ទាត់ត្រង់រាប់រយទៀតដែលគូសតាមចំណុចនោះតំណាងឲ្យការបកស្រាយខុសៗគ្នានៃព្រះគម្ពីរប៊ីប ហើយថាការបកស្រាយនីមួយៗនោះ តំណាងឲ្យព្រះវិហារខុសៗគ្នា ។

ទោះជាយ៉ាងណា តើអ្វីនឹងកើតឡើង ប្រសិនបើនៅលើក្រដាសនោះមានចំណុចទីពីរមួយដែលតំណាងឲ្យព្រះគម្ពីរមរមន ? តើមានបន្ទាត់ត្រង់ប៉ុន្មានដែលអ្នកអាចគូសបាននៅចន្លោះចំណុចតំណាងទាំងពីរនោះ---គម្ពីរប៊ីប និងគម្ពីរមរមន ? មានតែមួយបន្ទាត់ទេ---ការបកស្រាយតែមួយអំពីគោលលទ្ធិរបស់ព្រះគ្រីស្ទ អាចមានដោយសារតែទីបន្ទាល់នៃសាក្សីទាំងពីរនេះ ។

ព្រះគម្ពីរមរមនសម្តែងជាការបញ្ជាក់ ជាការធ្វើឲ្យច្បាស់ ជាការបង្រួបបង្រួមសាក្សីនៃគោលលទ្ធិដែលបានបង្រៀននៅក្នុងគម្ពីរប៊ីប ម្តងហើយម្តងទៀតថាមាន « ព្រះអម្ចាស់តែមួយ សេចក្តីជំនឿតែមួយ បុណ្យជ្រមុជទឹកតែមួយ » ។ ឧទាហរណ៍ មានមនុស្សមួយចំនួនបានយល់ច្រឡំថាតើពិធីបុណ្យជ្រមុជទឹកសំខាន់ ឬអត់សម្រាប់សេចក្តីសង្គ្រោះ សូម្បីតែព្រះអង្គសង្គ្រោះបានប្រកាសទៅកាន់នីកូដេមថា «ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ » ( យ៉ូហាន3:5 ) ។ ទោះជាយ៉ាងណា ព្រះគម្ពីរមរមនចាក់ទម្លុះនូវរាល់ការសង្ស័យទាំងឡាយពីប្រធានបទនោះថា ៖ «ហើយទ្រង់បញ្ជាមនុស្សលោកទាំងអស់ថា ពួកគេត្រូវតែប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹកដោយនូវព្រះនាមទ្រង់ ...បើពុំនោះសោតទេ ពួកគេមិនអាចបានសង្គ្រោះនៅក្នុងនគរនៃព្រះបានឡើយ » ( នីហ្វៃទី2 9:23 ) ។

មានរបៀបធ្វើបុណ្យជ្រមុជទឹកផ្សេងៗគ្នា នៅក្នុងពិភពលោកសព្វថ្ងៃនេះទោះបីជាព្រះគម្ពីរប៊ីប ប្រាប់យើងពីរបៀបដែលព្រះអង្គសង្គ្រោះ ដែលជាគំរូដ៏អស្ចារ្យរបស់យើងបានធ្វើក៏ដោយ៖ « [ ទ្រង់] យាងឡើងពីទឹកភ្លាម » (ម៉ាថាយ3:16 ) ។ តើទ្រង់មិនបានចេញពីទឹកដោយបានចុះទៅក្នុងទឹកជាមុនសិនទេឬអី ? លុះត្រាតែមានភាពមិនស៊ីគ្នាស្តីពីប្រធានបទនេះ ព្រះគម្ពីរមរមនបំបាត់ចម្ងល់ដោយថ្លែងចំៗដូចនេះអំពីគោលលទ្ធិ ស្របតាមរបៀបជ្រមុជទឹកដ៏ត្រឹមត្រូវថា ៖ « ហើយបន្ទាប់មកអ្នកត្រូវពន្លិចគេនៅក្នុងទឹក » ( នីហ្វៃទី3 11:26 ) ។

មនុស្សជាច្រើនជឿថា វិវរណៈបានបញ្ចប់ បន្ទាប់ពីគម្ពីរប៊ីប ទោះបីជាគម្ពីរប៊ីបផ្ទាល់ គឺជាទីបន្ទាល់អំពីគំរូ នៃវិវរណៈរបស់ព្រះជាង 4,000 ឆ្នាំនៃការរស់នៅរបស់មនុស្សក្តី ។ ប៉ុន្តែមានគោលលទ្ធិមិនពិតមួយ គឺដូចជាល្បែងដូមីណូដែលធ្វើឲ្យដូមីណូផ្សេងទៀតថយចុះ ឬក៏នៅក្នុងករណីនេះគឺជាការថយចុះនៃគោលលទ្ធិត្រឹមត្រូវ ។ ជំនឿលើការបញ្ចប់នៃវិវរណៈ បណ្តាលឲ្យគោលលទ្ធិដែលថាព្រះដូចម្សិលមិញ ថ្ងៃនេះ និងជារៀងរហូតធ្លាក់ចុះ វាបណ្តាលឲ្យគោលលទ្ធិដែលបានបង្រៀនដោយអេម៉ុសថា « ពិតប្រាកដជាព្រះយេហូវ៉ាទ្រង់ នឹងមិនធ្វើអ្វីដូច្នោះឡើយ លើកលែងតែទ្រង់សម្តែងឲ្យពួកហោរាជាអ្នកបម្រើទ្រង់ឃើញគំនិតលាក់កំបាំងរបស់ទ្រង់ផង » ( អេម៉ុស3:7 ) ថយចុះ ហើយវាបណ្តាលឲ្យគោលលទ្ធិដែលថា «ព្រះមិនរើសមុខអ្នកណាទេ» ( កិច្ចការ 10:34 ) និយាយទៅកាន់មនុស្សគ្រប់វ័យទាំងអស់ថយចុះ ។ តែជាការល្អណាស់ ដែលព្រះគម្ពីរមរមន គ្រងរាជសារជាថ្មីលើសេចក្តីពិតក្នុងគម្ពីរប៊ីបដោយបន្តមាន វិវរណៈ ៖ «ហើយម្យ៉ាងទៀត ខ្ញុំសូមប្រាប់អ្នកណាដែលបដិសេធវិវរណៈទាំងឡាយនៃព្រះ ហើយដែលនិយាយថាឥតមានការណ៍ទាំងនោះឡើយ ថាគ្មានវិវរណៈ ... ត្បិតតើពុំមែនពួកយើងបានអានហើយឬអីថា ព្រះនៅតែដដែលទោះថ្ងៃម្សិល ថ្ងៃនេះ និងរហូតតទៅ » (មរមន 9:7,9 ) ។ ម្យ៉ាងវិញទៀត បើព្រះដែលពុំចេះផ្លាស់ប្តូរ បានមានបន្ទូលកាលពីបុរាណ នោះទ្រង់នឹងធ្វើដូចគ្នានៅក្នុងសម័យនេះដែរ ។

គ្មានអារម្មណ៍ណាដែលមានខ្លាំងជាងឥទ្ធិពលព្រះគម្ពីរមរមន្តអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទនោះទេ ។ តើអ្នកចង់បានសេចក្ដីបញ្ជាក់ដល់ព្រលឹងរបស់អ្នកតាមរយៈសាក្សីមួយដែលពុំអាចបដិសេធបានដែលថាព្រះអង្គសង្គ្រោះបានធ្លាក់ចុះដោយបាបរបស់អ្នក ហើយថាគ្មានអំពើបាប គ្មានស្ថានភាពដ៏លំបាកខាងមតភាពណាក្រៅពីសេចក្ដីមេត្តាករុណាឈោងទៅកដង្វាយធួនរបស់ទ្រង់---ហើយថារាល់ឧបសគ្គរបស់អ្នកទ្រង់មានដំណោះស្រាយពីអំណាចព្យាបាលដ៏ខ្ពស់ដែរឬទេ ? នោះត្រូវអានព្រះគម្ពីរមរមន ។ វានឹងបង្រៀន និងធ្វើបន្ទាល់ដល់អ្នកថាដង្វាយ ធួនរបស់ព្រះគ្រីស្ទ គឺគ្មានទីបញ្ចប់ ពីព្រោះវាគ្របដណ្ដប់ និងអស្ចារ្យជាងរាល់ភាពទន់ខ្សោយក្នុងជីវិតរមែងស្លាប់ ដែលមនុស្សអាចដឹងបាន ។ នោះជាមូលហេតុដែលព្យាការីមរមន បានប្រកាសថា « អ្នករាល់គ្នានឹងមានសេចក្ដីសង្ឃឹម តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ » (មរ៉ូណៃ7:41 ) ។

គ្មានចម្ងល់ទេដែល ព្រះគម្ពីរមរមនប្រកាសដោយក្លាហានថា «ហើយបើសិនជាអ្នកជឿដល់ព្រះគ្រីស្ទ នោះអ្នករាល់គ្នានឹងក៏នឹងជឿដល់ពាក្យទាំងនេះដែរ ព្រោះពាក្យទាំងនេះ គឺជាព្រះបន្ទូលនៃព្រះគ្រីស្ទ » ( នីហ្វៃទី2 33:10 ) ។ រួមគ្នាជាមួយនឹងព្រះគម្ពីរប៊ីប ព្រះគម្ពីរមរមនជាសាក្សីដ៏សំខាន់អំពីគោលលទ្ធិរបស់ព្រះគ្រីស្ទ និងទេវភាពរបស់ទ្រង់ ។ រួមគ្នាជាមួយនឹងព្រះគម្ពីរប៊ីប វា «ប្រដៅ] មនុស្សទាំងអស់ឲ្យធ្វើអំពើល្អ » (នីហ្វៃទី2 33:10 )។ ហើយរួមគ្នាជាមួយនឹងគម្ពីរប៊ីប វានាំយើងទៅរក « ព្រះអម្ចាស់តែមួយ សេចក្ដីជំនឿតែមួយ បុណ្យជ្រមុជទឹកតែមួយ » ។ នោះជាមូលហេតុដែលព្រះគម្ពីរមរមនសំខាន់ក្នុងជីវិតយើង ។

ជាច្រើនឆ្នាំកន្លងមកហើយ ខ្ញុំបានចូលរួមការប្រជុំថ្វាយបង្គំរបស់យើងនៅទីក្រុង តូរ៉ុនតូ ប្រទេស កាណាដា ។ មានយុវនារីអាយុ 14 ឆ្នាំម្នាក់ជាអ្នកឡើងនិយាយ ។ នាងបាននិយាយថា នាងបានពិភាក្សាពីសាសនាជាមួយនឹងមិត្តភក្តិទាំងឡាយរបស់នាងនៅឯសាលា ។ មិត្តរបស់នាងនិយាយទៅកាន់នាងថា « យើងអ្នកជឿលើសាសនាណា ? » នាងបានឆ្លើយថា «សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ឬមរមន » ។

មិត្តនាងបានឆ្លើយថា « ខ្ញុំស្គាល់សាសនាចក្រនោះ ហើយខ្ញុំដឹងថា វាមិនពិតទេ » ។ យុវនារីនោះឆ្លើយតបថា « តើអ្នកដឹងដោយរបៀបណា ? » ។<br>
មិត្តនាងបានឆ្លើយថា « ពីព្រោះ» «ខ្ញុំបានស្រាវជ្រាវពីវា» ។<br>
« តើអ្នកធ្លាប់អានព្រះគម្ពីរមរមនទេ ? »<br>
ចម្លើយ « ទេ » «ខ្ញុំមិនធ្លាប់អានទេ» ។

បន្ទាប់មកយុវនារីនេះបានឆ្លើយវិញថា « អញ្ចឹងអ្នកមិនទាន់បានស្រាវជ្រាវពីសាសនាចក្ររបស់ខ្ញុំនៅឡើយទេ ពីព្រោះខ្ញុំបានអានគ្រប់ទំព័រទាំងអស់នៃព្រះគម្ពីរមរមន ហើយខ្ញុំដឹងថាវាពិត» ។

ខ្ញុំក៏បានអានព្រះគម្ពីរមរមនម្ដងហើយម្ដងទៀត ហើយខ្ញុំសូមថ្លែងទីបន្ទាល់ដ៏រឹងមាំដូចជាលោកតាលួតរបស់ខ្ញុំថា ព្រះគម្ពីរមរមនមកពីព្រះ។ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អម៉ែន ។

កំណត់ចំណាំ

1. Willard Richards, in LeGrand Richards, *A Marvelous Work and a Wonder* (ឆ្នាំ1972) ទំព័រ 81, 82 ។

2. C. S. Lewis, *Mere Christianity* (ឆ្នាំ1952)ទំព័រ 40—41 ។